# ៣.អានន្ទត្ថេរគាថា

## អានន្ទត្ថេរគាថា

(បិ-៥៧ ទំ-៩៣)

១០១៧. "បិសុណេន ច កោធនេន ច, មច្ឆរិនា ច វិភូតនន្ទិនា;
សខិតំ ន ករេយ្យ បណ្ឌិតោ, បាបោ កាបុរិសេន សង្គមោ។

*[២៦១] បណ្ឌិតមិនគួរធ្វើសខិភាព គឺភាពជាសម្លាញ់នឹងបុគ្គលអ្នកញុះញង់ អ្នកក្រេវក្រោធ អ្នកកំណាញ់ ទាំងជាអ្នកត្រេកអរនឹងសេចក្ដីវិនាសទេ (ព្រោះថា) ការសេពគប់នឹងបុរសអាក្រក់ ជាអំពើដ៏លាមក ។*

១០១៨. សទ្ធេន ច បេសលេន ច, បញ្ញវតា ពហុស្សុតេន ច;
សខិតំ ករេយ្យ បណ្ឌិតោ, ភទ្ទោ សប្បុរិសេន សង្គមោ។

*បណ្ឌិតគួរធ្វើសខិភាព នឹងបុគ្គលអ្នកមានសទ្ធា មានសីលជាទីស្រឡាញ់ អ្នកមានប្រាជ្ញា មានការចេះដឹងច្រើន (ព្រោះថា) ការសេពគប់នឹងពួកសប្បុរស ជាការចម្រើន ។*

១០១៩. បស្ស ចិត្តកតំ ពិម្ពំ, អរុកាយំ សមុស្សិតំ;
អាតុរំ ពហុសង្កប្បំ, យស្ស នត្ថិ ធុវំ ឋិតិ។

*អ្នកចូរមើលនូវពុម្ព គឺអត្តភាពដែលធ្វើឲ្យវិចិត្រ ជាទីប្រជុំនៃដំបៅ ផ្គុំឡើង (ដោយឆ្អឹង ៣០០ កំណាត់) ជាគ្រឿងពោលពល ជាទីប្រាថ្នានៃជនច្រើន ជាកាយឥតទៀងទាត់បិតថេរ។*

១០២០. បស្ស ចិត្តកតំ រូបំ, មណិនា កុណ្ឌលេន ច;
អដ្ឋឹ តចេន ឱនទ្ធំ, សហ វត្ថេហិ សោភតិ។

*អ្នកចូរមើលនូវរូប ដែលធ្វើឲ្យវិចិត្រដោយកែវមណី និងកណ្ឌល ដែលឆ្អឹង និងស្បែករួបរឹតហើយ (រូបនោះ) រមែងល្អដោយសារសំពត់ទាំងឡាយ ។*

១០២១. អលត្តកកតា បាទា, មុខំ ចុណ្ណកមក្ខិតំ;
អលំ ពាលស្ស មោហាយ, នោ ច បារគវេសិនោ។

*ដើងទាំងឡាយ លាបដោយល័ខស្រស់ មុខលាបដោយគ្រឿងលំអិត អាចញ៉ាំងជនពាលឲ្យវង្វេង តែមិនអាចញ៉ាំងបុគ្គលអ្នកស្វែងរកនូវត្រើយ គឺព្រះនិព្វានឲ្យវង្វេងបានទេ ។*

១០២២. អដ្ឋបទកតា កេសា, នេត្តា អញ្ជនមក្ខិតា;
អលំ ពាលស្ស មោហាយ, នោ ច បារគវេសិនោ។

*សក់ទាំងឡាយ ដែលគេរចនាដូចជាក្រឡាចតុរង្គ ភ្នែកទាំងឡាយ លាបដោយថ្នាំសម្រាប់បន្តក់ភ្នែក អាចញ៉ាំងជនពាលឲ្យវង្វេង តែមិនអាចញ៉ាំងបុគ្គលអ្នកស្វែងរកនូវត្រើយ គឺព្រះនិព្វានឲ្យវង្វេងបានឡើយ ។*

១០២៣. អញ្ជនីវ នវា ចិត្តា, បូតិកាយោ អលង្កតោ;
អលំ ពាលស្ស មោហាយ, នោ ច បារគវេសិនោ។

*កាយស្អុយដែលគេតាក់តែងហើយ ដូចជានាឡិសម្រាប់ដាក់ថ្នាំបន្តក់ ដែលគេវិចិត្រហើយថ្មី ៗ អាចញ៉ាំងជនពាលឲ្យវង្វេង តែមិនអាចញ៉ាំងបុគ្គលអ្នកស្វែងរកនូវត្រើយ គឺព្រះនិព្វានឲ្យវង្វេងបានឡើយ ។*

១០២៤. ពហុស្សុតោ ចិត្តកថី, ពុទ្ធស្ស បរិចារកោ;
បន្នភារោ វិសញ្ញុត្តោ, សេយ្យំ កប្បេតិ គោតមោ។

*ព្រះអានន្ទត្ថេរ ជាគោតមគោត្ត ជាអ្នកចេះដឹងច្រើន មានវាចាដ៏វិចិត្រ ជាអ្នកបម្រើនូវព្រះពុទ្ធ បានដាក់ចុះនូវភារៈ ជាអ្នកប្រាសចាកកិលេស ជាគ្រឿងប្រកប សម្រេចនូវការសិង ។*

១០២៥. ខីណាសវោ វិសញ្ញុត្តោ, សង្គាតីតោ សុនិព្ពុតោ;
ធារេតិ អន្តិមំ ទេហំ, ជាតិមរណបារគូ។

*ព្រះអានន្ទត្ថេរ ជាខីណាស្រព ប្រាសចាកកិលេស ជាគ្រឿងប្រកប កន្លងនូវកិលេសជាគ្រឿងជាប់ជំពាក់ មានចិត្តត្រជាក់ល្អ ដល់នូវត្រើយនៃជាតិ និងមរណៈ ទ្រទ្រង់ទុកនូវអត្តភាព ជាបំផុត ។*

១០២៦. យស្មឹ បតិដ្ឋិតា ធម្មា, ពុទ្ធស្សាទិច្ចពន្ធុនោ;
និព្ពានគមនេ មគ្គេ, សោយំ តិដ្ឋតិ គោតមោ។

*សាសនធម៌ទាំងឡាយ របស់ព្រះពុទ្ធ ជាអាទិច្ចពន្ធុ ប្រតិស្ឋានក្នុងព្រះអានន្ទត្ថេរណា ព្រះអានន្ទត្ថេរនោះ ជាគោតមគោត្ត ឋិតនៅក្នុងផ្លូវជាទីទៅកាន់ព្រះនិព្វាន ។*

១០២៧. ទ្វាសីតិ ពុទ្ធតោ គណ្ហឹ, ទ្វេ សហស្សានិ ភិក្ខុតោ;
ចតុរាសីតិសហស្សានិ, យេ មេ ធម្មា បវត្តិនោ។

*សាសនធម៌ទាំងឡាយណា ដែលប្រព្រឹត្តទៅ (ក្នុងហឫទ័យ) របស់ខ្ញុំ សាសនធម៌ទាំងឡាយនោះ មាន ៨ ម៉ឺន ៤ ពាន់ធម្មក្ខន្ធ ខ្ញុំបានរៀនអំពីព្រះពុទ្ធ ៨ ម៉ឺន ២ ពាន់ធម្មក្ខន្ធ អំពីពួកភិក្ខុ ២ ពាន់ធម្មក្ខន្ធ ។*

១០២៨. អប្បស្សុតាយំ បុរិសោ, ពលិពទ្ទោវ ជីរតិ;
មំសានិ តស្ស វឌ្ឍន្តិ, បញ្ញា តស្ស ន វឌ្ឍតិ។

*បុរសនេះ មិនបានរៀនសូត្រ រមែងចាស់ (ឥតអំពើ) ដូចគោបម្រើ ចម្រើនតែសាច់ ត្រង់ប្រាជ្ញារបស់វា មិនចម្រើនឡើយ ។*

១០២៩. ពហុស្សុតោ អប្បស្សុតំ, យោ សុតេនាតិមញ្ញតិ;
អន្ធោ បទីបធារោវ, តថេវ បដិភាតិ មំ។

*បុគ្គលណា ជាអ្នករៀនសូត្រច្រើន ហើយមើលងាយបុគ្គលអ្នកមិនបានរៀនសូត្រ ដោយការរៀនសូត្រ (របស់ខ្លួន) បុគ្គលនោះ ដូចមនុស្សខ្វាក់ កាន់ប្រទីប រមែងភ្លឺច្បាស់ដល់ខ្ញុំយ៉ាងនេះឯង ។*

១០៣០. ពហុស្សុតំ ឧបាសេយ្យ, សុតញ្ច ន វិនាសយេ;
តំ មូលំ ព្រហ្មចរិយស្ស, តស្មា ធម្មធរោ សិយា។

*បុគ្គលគួរចូលទៅអង្គុយជិតនឹងអ្នករៀនសូត្រច្រើនផង មិនគប្បីញុំាងការរៀនសូត្រឲ្យវិនាសផង (ព្រោះថា) ការរៀនសូត្រនោះ ជាឫសគល់នៃព្រហ្មចរិយធម៌ ហេតុនោះ បុគ្គលគួរជាអ្នកទ្រទ្រង់ធម៌ ។*

១០៣១. បុព្ពាបរញ្ញូ អត្ថញ្ញូ, និរុត្តិបទកោវិទោ;
សុគ្គហីតញ្ច គណ្ហាតិ, អត្ថញ្ចោបបរិក្ខតិ។

បុគ្គលអ្នកចេះដឹង នូវខាងដើម និងខាងចុង (នៃភាសិត) ជាអ្នកដឹងអត្ថ ឈ្លាសវៃក្នុងនិរុត្តិ (ភាសា) និងបទ (ដ៏សេស) រមែងកាន់យកនូវធម៌ឲ្យជាធម៌ ដែលកាន់យកល្អហើយផង ពិចារណានូវសេចក្តីផង ។

១០៣២. ខន្ត្យា ឆន្ទិកតោ ហោតិ, ឧស្សហិត្វា តុលេតិ តំ;
សមយេ សោ បធហតិ, អជ្ឈត្តំ សុសមាហិតោ។

បុគ្គលអ្នកមានសេចក្តីប្រាថ្នា (ក្នុងធម៌) ដោយសេចក្តីអត់ធន់ រមែងខ្មីឃ្មាត ពិចារណានូវនាមរូបនោះ បុគ្គលនោះ មានចិត្តតាំងមាំល្អខាងក្នុងសន្តាន រមែងផ្គងចិត្តទុកក្នុងសម័យដ៏គួរ ។

១០៣៣. ពហុស្សុតំ ធម្មធរំ, សប្បញ្ញំ ពុទ្ធសាវកំ;
ធម្មវិញ្ញាណមាកង្ខំ, តំ ភជេថ តថាវិធំ។

បុគ្គលកាលប្រាថ្នានូវការដឹងធម៌ គប្បីគប់រកអ្នករៀនសូត្រច្រើន អ្នកចងចាំនូវធម៌ អ្នកមានប្រាជ្ញា ជាសាវ័ករបស់ព្រះពុទ្ធ បែបដូច្នោះនោះ ។

១០៣៤. ពហុស្សុតោ ធម្មធរោ, កោសារក្ខោ មហេសិនោ;
ចក្ខុ សព្ពស្ស លោកស្ស, បូជនីយោ ពហុស្សុតោ។

បុគ្គលអ្នករៀនសូត្រច្រើន រមែងអ្នកចងចាំនូវធម៌ អ្នករក្សាទុកនូវឃ្លាំងធម៌របស់ព្រះពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ធំ ឯបុគ្គលអ្នករៀនសូត្រច្រើននោះ ឈ្មោះថា ជាចក្ខុរបស់សត្វលោកទាំងពួង ជាបុគ្គលគួរគេបូជា ។

១០៣៥. ធម្មារាមោ ធម្មរតោ, ធម្មំ អនុវិចិន្តយំ;
ធម្មំ អនុស្សរំ ភិក្ខុ, សទ្ធម្មា ន បរិហាយតិ។

ភិក្ខុមានធម៌ជាទីត្រេកអរ ត្រេកអរក្នុងធម៌ កាលគិតរឿយ ៗ នូវធម៌ រលឹករឿយ ៗ នូវធម៌ រមែងមិនសាបសូន្យចាកព្រះសទ្ធម្ម ។

១០៣៦. កាយមច្ឆេរគរុនោ, ហិយ្យមានេ អនុដ្ឋហេ;
សរីរសុខគិទ្ធស្ស, កុតោ សមណផាសុតា។

*បុគ្គលអ្នកធ្ងន់ដោយសេចក្តីកំណាញ់ (ថ្នម) កាយ (កាលបើកាយ និងជីវិត) សាបសូន្យទៅ ក៏មិនខ្មីឃ្មាត (ចំពោះកិច្ចគួរធ្វើ) បុគ្គលអ្នកជាប់ចំពាក់ដោយសេចក្តីសុខក្នុងសរីរៈ តើសេចក្តីសប្បាយ ដោយសមណភាព (នឹងមានមក) អំពីទីណា ។*

១០៣៧. ន បក្ខន្តិ ទិសា សព្ពា, ធម្មា ន បដិភន្តិ មំ;
គតេ កល្យាណមិត្តម្ហិ, អន្ធការំវ ខាយតិ។

*ទិសទាំងអស់ រមែងមិនប្រាកដ ធម៌មិនភ្លឺច្បាស់ដល់ខ្ញុំ កាលបើព្រះសារីបុត្ត ជាកល្យាណមិត្ត (ទៅកាន់និព្វាន) ហើយ សត្វលោក ប្រាកដដូចជាទីងងឹត ។*

១០៣៨. អព្ភតីតសហាយស្ស, អតីតគតសត្ថុនោ;
នត្ថិ ឯតាទិសំ មិត្តំ, យថា កាយគតា សតិ។

*បុគ្គលដែលមានសម្លាញ់ព្រាត់ប្រាសហើយ មានសាស្តាកន្លងទៅហើយ រមែងមិនមានមិត្តបែបនុ៎ះ ដូចជាកាយគតាសតិឡើយ ។*

១០៣៩. យេ បុរាណា អតីតា តេ, នវេហិ ន សមេតិ មេ;
ស្វជ្ជ ឯកោវ ឈាយាមិ, វស្សុបេតោវ បក្ខិមា។

*ពួកព្រះថេរៈណាចាស់ ៗ ពួកព្រះថេរៈនោះ កន្លងទៅហើយ ចិត្តរបស់ខ្ញុំមិនល្មមនឹងភិក្ខុថ្មីៗថ្ងៃនេះខ្ញុំចម្រើនឈានតែម្នាក់ឯង ដូចសត្វបក្សីចូលទៅសម្ងំក្នុងសម្បុកក្នុងរដូវភ្លៀង ។*

១០៤០. ទស្សនាយ អភិក្កន្តេ, នានាវេរជ្ជកេ ពហូ;
មា វារយិត្ថ សោតារោ, បស្សន្តុ សមយោ មមំ។

*អ្នកកុំឃាត់ពួកជនច្រើននៅក្នុងប្រទេសផ្សេង ៗ ដែលពុំទាន់បានចួប ឯពួកអ្នកស្តាប់ចូរមកចួបចុះ ព្រោះថាជាសម័យ (គួរចួប) នឹងខ្ញុំហើយ ។*

១០៤១. ទស្សនាយ អភិក្កន្តេ, នានាវេរជ្ជកេ បុថុ;
ករោតិ សត្ថា ឱកាសំ, ន និវារេតិ ចក្ខុមា។

*ព្រះសាស្តាមានចក្ខុ ទ្រង់ប្រទានឱកាស មិនហាមឃាត់ពួកជនច្រើន នៅក្នុងប្រទេសផ្សេង ៗ ដែលពុំទាន់បានចួប ។*

១០៤២. បណ្ណវីសតិវស្សានិ, សេខភូតស្ស មេ សតោ;
ន កាមសញ្ញា ឧប្បជ្ជិ, បស្ស ធម្មសុធម្មតំ។

*កាលខ្ញុំនៅជាសេក្ខបុគ្គល អស់ ២៥ ឆ្នាំ កាមសញ្ញាមិនកើតឡើងទេ អ្នកចូរមើលនូវសភាពល្អរបស់ធម៌ចុះ ។*

១០៤៣. បណ្ណវីសតិវស្សានិ, សេខភូតស្ស មេ សតោ;
ន ទោសសញ្ញា ឧប្បជ្ជិ, បស្ស ធម្មសុធម្មតំ។

*កាលខ្ញុំនៅជាសេក្ខបុគ្គល អស់ ២៥ ឆ្នាំ ទោសសញ្ញាមិនកើតឡើងទេ អ្នកចូរមើលនូវភាពល្អរបស់ធម៌ចុះ ។*

១០៤៤. បណ្ណវីសតិវស្សានិ, ភគវន្តំ ឧបដ្ឋហិំ;
មេត្តេន កាយកម្មេន, ឆាយាវ អនបាយិនី។

*ខ្ញុំបានបម្រើព្រះមានព្រះភាគ ដោយកាយកម្ម ប្រកបដោយមេត្តា អស់ ២៥ ឆ្នាំ ដូចជាស្រមោលជាប់តាមរូប ។*

១០៤៥. បណ្ណវីសតិវស្សានិ, ភគវន្តំ ឧបដ្ឋហិំ;
មេត្តេន វចីកម្មេន, ឆាយាវ អនបាយិនី។

*ខ្ញុំបានបម្រើព្រះមានព្រះភាគ ដោយវចីកម្ម ប្រកបដោយមេត្តា អស់ ២៥ ឆ្នាំ ដូចជាស្រមោលជាប់តាមរូប ។*

១០៤៦. បណ្ណវីសតិវស្សានិ, ភគវន្តំ ឧបដ្ឋហិំ;
មេត្តេន មនោកម្មេន, ឆាយាវ អនបាយិនី។

*ខ្ញុំបានបម្រើព្រះមានព្រះភាគ ដោយមនោកម្មប្រកបដោយមេត្តា អស់ ២៥ ឆ្នាំ ដូចជាស្រមោលជាប់តាមរូប ។*

១០៤៧. ពុទ្ធស្ស ចង្កមន្តស្ស, បិដ្ឋិតោ អនុចង្កមិំ;
ធម្មេ ទេសិយមានម្ហិ, ញាណំ មេ ឧទបជ្ជថ។

*កាលព្រះពុទ្ធម្ចាស់ ទ្រង់ចង្រ្កម ខ្ញុំបានចង្រ្កមតាមក្រោយព្រះអង្គ នាកាលធម៌ដែលព្រះអង្គសំដែង ញាណរបស់ខ្ញុំក៏កើតឡើង ។*

១០៤៨. អហំ សករណីយោម្ហិ, សេខោ អប្បត្តមានសោ;
សត្ថុ ច បរិនិព្ពានំ, យោ អម្ហំ អនុកម្បកោ។

*ខ្ញុំជាសេក្ខបុគ្គល ប្រកបដោយកិច្ច មានសេចក្តីប្រាថ្នាក្នុងចិត្តមិនទាន់សម្រេច (អរហត្តផល) ព្រះសាស្តា ព្រះអង្គអនុគ្រោះខ្ញុំ ទ្រង់បរិនិព្វាន ។*

១០៤៩. តទាសិ យំ ភឹសនកំ, តទាសិ លោមហំសនំ;
សព្ពាការវរូបេតេ, សម្ពុទ្ធេ បរិនិព្ពុតេ។

*កាលព្រះសម្ពុទ្ធ ប្រកបដោយអាការដ៏ប្រសើរគ្រប់យ៉ាង ទ្រង់បរិនិព្វានហើយ សេចក្តីស្ញប់ស្ញែងនៃខ្ញុំក៏កើតមាន សេចក្តីព្រឺរោមនៃខ្ញុំក៏កើតមាន ។*

១០៥០. ពហុស្សុតោ ធម្មធរោ, កោសារក្ខោ មហេសិនោ;
ចក្ខុ សព្ពស្ស លោកស្ស, អានន្ទោ បរិនិព្ពុតោ។

*ព្រះអានន្ទ ជាពហុស្សូត អ្នកចងចាំនូវធម៌ រក្សាទុកនូវឃ្លាំងធម៌នៃព្រះពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ប្រសើរ លោកជាចក្ខុនៃសត្វលោកទាំងអស់ បរិនិព្វានហើយ ។*

១០៥១. ពហុស្សុតោ ធម្មធរោ, កោសារក្ខោ មហេសិនោ;
ចក្ខុ សព្ពស្ស លោកស្ស, អន្ធការេ តមោនុទោ។

*ព្រះអានន្ទ ជាពហុស្សូត អ្នកចងចាំនូវធម៌ ជាឃ្លាំងរក្សាទុកនូវធម៌នៃព្រះពុទ្ធ ទ្រង់ស្វែងរកនូវគុណដ៏ប្រសើរ លោកជាចក្ខុនៃសត្វលោកទាំងអស់ ជាអ្នកបន្ទោបង់នូវងងឹត ក្នុងទីដ៏ងងឹត ។*

១០៥២. គតិមន្តោ សតិមន្តោ, ធិតិមន្តោ ច យោ ឥសិ;
សទ្ធម្មធារកោ ថេរោ, អានន្ទោ រតនាករោ។

*ព្រះអានន្ទត្ថេរ មានញាណគតិ មានស្មារតី មានប្រាជ្ញា ជាគ្រឿងទ្រទ្រង់ ជាអ្នកស្វែងរកនូវគុណ ទ្រទ្រង់ទុកនូវព្រះសទ្ធម្ម ជាអណ្តូងនៃធម្មរតនៈ ។*

១០៤៣. បរិចិណ្ណោ មយា សត្ថា, កតំ ពុទ្ធស្ស សាសនំ;
ឱហិតោ គរុកោ ភារោ, នត្ថិ ទានិ បុនព្ភវោ"តិ។

*ព្រះសាស្តា ខ្ញុំបានបម្រើហើយ សាសនារបស់ព្រះពុទ្ធ ខ្ញុំបានធ្វើហើយ ភារៈធ្ងន់ខ្ញុំបានដាក់ចុះហើយ តណ្ហាជាគ្រឿងនាំទៅកាន់ភព ខ្ញុំក៏បានដកចេញហើយ ។*

... **អានន្ទោ ថេរោ**... *អានន្ទត្ថេរ ។*

**តឹសនិបាតោ និដ្ឋិតោ។**

*តឹសនិបាត ចប់។*

**តត្រុទ្ទានំ –**

***ឧទ្ទាន***

ផុស្សោបតិស្សោ អានន្ទោ, តយោតិមេ បកិត្តិតា;
គាថាយោ តត្ថ សង្ខាតា, សតំ បញ្ច ច ឧត្តរីតិ;។

*ព្រះថេរៈ ៣ អង្គនេះ គឺ ព្រះបុស្សៈ ១ ព្រះឧបតិស្សៈ ១ ព្រះអានន្ទ ១ លោកបានសំដែងគាថា ដែលបានពោលទុកក្នុងទីនោះ ១០៥ គាថា ។*